## បទសុធ្យបទ្ធតទច់

## ព្រះពុទ្ធសាសនា

១. សូមមើលទង់ជ័យ ឆព្វណ្ណរង្សី    ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស    ហង្សបាទ និងពណ៌ដ៏ភ្លឺផ្លេក ។
២. ប្រទេសតូចធំ បានស្ម័គ្រស្មាគម    ជំនុំគ្នាច្រើន    អនេក
ព្រមយករស្មី ព្រះពុទ្ធគួរគ្រេក    ប្រសើរ ពន់ពេកក្រៃកន្លង ។
៣. ធ្វើជាសញ្ញា ទង់ជ័យសាសនា    នៃសមុទ្ទធំ  ចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង    នឹកដល់ព្រះអង្គ ជាអម្ចាស់ ។
៤. ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា    សុទ្ធសឹងតែជា ពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់    ប្រឹងប្រែង ឲ្យណាស់គ្រប់ៗគ្នា ។
៥. សូមសាសនាពុទ្ធ ថ្កុំថ្កើងបំផុត    រុងរឿងវិសុទ្ធិ ថ្លៃថ្លា ហើយមាន
ជ័យជោគ ផ្សាយពេញលោកា    ដោយជនជ្រះថ្លា ច្រើនសែនលាន ។
៦. មានចិត្តស្នេហា គោរពបូជា    ចំពោះធម៌ដ៏ កល្យាណ
ទាំងមនុស្សទេព្តា ស្នេហាគ្រប់ប្រាណ    ប្រាថ្នាចង់បានសេចក្តីសុខ ។
៧. យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត    កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ    យើងនឹង បានសុខក្សេមក្សាន្តត្រាណ ។
៨. ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត    ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត    ជាតិយើងនឹងបានសោយសុខា ។

# បទសូធ្យពេលឆន់បន្ទូតហើយ

## ព្រះពុទ្ធសាសនា

១. ជាតិយើងអ្នកកាន់សាសនា　　ត្រូវដឹងច្បាស់ថា ព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី　　គឺព្រះរស្មី ទាំងប្រាំមួយពណ៌ ។
២. ផ្សាយចេញពីព្រះកាយទ្រង់　　រុងរឿងឫទ្ធិរុង ប្រសើរបវរ
ធ្វៀលធ្វាត់កាយឆើតឆាយល្អ　　ទាំងប្រាំមួយពណ៌ ស្រស់ល្អសោភា ។
៣. កំណើតនៃព្រះរស្មី　　កើតដោយបារមី នៃព្រះភគវា
ធ្វើទានឥតមានរុញរា　　កាលដែលនៅជា ព្រះពោធិសត្វ ។
៤. រស្មីពណ៌ខៀវនោះណា　　កាលឆ្កៀលនេត្រា ទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត　　កាលនៅជាក្សត្រ នាមស្រីពិភស្ត្រ ។
៥. រស្មីពណ៌លឿងភ្លឺថ្លា　　កាលដែលទ្រង់អារ សាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស　　ព្រះឥន្ទជាងមាស ទ្រង់វៃបណ្ឌិត ។
៦. រស្មីក្រហមនោះណា　　កាលដែលមាតា ពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត　　កាត់បេះដូងបិទ ធ្វើថ្នាំមាតា ។
៧. រស្មីពណ៌សសុទ្ធសាធ　　កាលជាព្រះបាទ វេស្សន្តរក្សត្រា
ឲ្យទានដំរីសសោភា　　ដែលទ្រង់ប្រាថ្នា យកពោធិញ្ញាណ ។
៨. រស្មីពណ៌ដូចជើងហង្ស　　កាលមាតាទ្រង់ យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ　　ឲ្យយក្សសាមាន្យ ស៊ីប្តូរជីវិត ។
៩. រស្មីភ្លឺផ្លេកពណ្ណរាយ　　កាលជាទន្សាយ ឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត　　ដល់ឥន្ទព្រាហ្មណ៍ពិត ថាអត់អាហារ ។
១០.រស្មី-ខៀវ-លឿង-ក្រហម　　ស-ហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ　　ក្មេងចាស់កុមារ ចងចាំទុកអើយ ។